សុន្ទរកថារបស់**លោក តាខាមូរ៉ា ហ៊ីរ៉ូស៊ី** ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិរបស់ប្រទេសជប៉ុន

១៦ មិនា ២០១២

**សូមគោរព លោក លី ជុងថេង ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល!**
**សូមគោរព លោកស្រី ឈិន សុវណ្ណ នាយកាសាលាគរុកោសល្យ និងវិក្រឹតការខេត្តកណ្តាល!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយ សាលាគរុកោសល្យ និងវិក្រឹតការខេត្តកណ្តាលសម្រាប់គម្រោងសាងសង់អគារពិសោធន៍វិទ្យាសាស្ត្រមួយខ្នង។

ការអភិវឌ្ឍធនធានមនុស្សគឺជាកត្តាមូលដ្ឋានដើម្បីអភិវឌ្ឍប្រទេសកម្ពុជានាពេលអនាគត។ ក្នុងគោលបំណងដើម្បីបង្កើនគុណភាពនៃការអប់រំមុខវិជ្ជាវិទ្យាសាស្ត្រ JICA បានផ្តល់នូវវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅសាលាគរុកោសល្យ និងវិក្រឹតការភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការខេត្តជាច្រើនតាំងពីឆ្នាំ២០០៨មកម្ល៉េះ។ គម្រោងសាងសង់អគារពិសោធន៍វិទ្យាសាស្ត្រនេះបានផ្សារភ្ជាប់យ៉ាងស្អិតរមួតជាមួយនឹងការបណ្តុះបណ្តាលគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ហើយយើងរំពឹងថា ការរួមបញ្ចូលគ្នានេះនឹងបង្កើតនូវប្រសិទ្ធភាពដ៏លើសលប់មួយ។

ជំនួយដើម្បីសាងសង់អគារពិសោធន៍វិទ្យាសាស្ត្រមួយខ្នងនិងបំពាក់បរិក្ខារសិក្សានៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តកណ្តាលដែលផ្តល់ជូនថ្ងៃនេះនឹងធ្វើឲ្យសាស្ត្រាចារ្យ និងគរុសិស្សអាចសិក្សា និងធ្វើការពិសោធន៍លើមុខវិជ្ជាវិទ្យាសាស្ត្រដោយគ្មានការលំបាក។

គម្រោងនេះនឹងផ្តល់ការអប់រំមុខវិជ្ជាវិទ្យាសាស្ត្រកាន់តែប្រសើរដល់គរុសិស្សប្រមាណ២៤០នាក់ដែលនឹងក្លាយជាគ្រូបង្រៀនបឋមសិក្សានៅក្នុងខេត្តកណ្តាលបន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល។ យើងរំពឹងថាសិស្សានុសិស្សបឋមសិក្សាប្រមាណ១៨០,០០០នាក់នៅក្នុងខេត្តនឹងអាចទទួលបានការអប់រំមុខវិជ្ជាវិទ្យាសាស្ត្រកាន់តែប្រសើរឡើងពីលោកគ្រូ អ្នកគ្រូទើបចេញថ្មីទាំងនេះ។

ខ្ញុំសង្ឃឹមថា គម្រោងដែលចុះហត្ថលេខាក្នុងថ្ងៃនេះនឹងត្រូវបានអនុវត្តដោយរលូន និងបានថែទាំយ៉ាងត្រឹមត្រូវដោយដោយភាគីដែលពាក់ព័ន្ធដែលនឹងរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាព រវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!